អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ

នៅក្នុងសេចក្តីសម្រេចចេញថ្ងៃនេះ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពន្យារពេលឃុំខ្លួន អៀង ធីរិទ្ធ បណ្តោះអាសន្ន និងបដិសេធសំណើសុំដោះលែងក្រៅឃុំ។ ក្រោយពីចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ អៀង ធីរិទ្ធ អាចស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។

អៀង ធីរិទ្ធ ដែលកាន់តួនាទីជារដ្ឋមន្ត្រីសង្គមកិច្ចអំឡុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ(សំណុំរឿងនេះកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនៅឡើយ)។ អៀង ធីរិទ្ធ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ បន្ទាប់មកត្រូវដាក់ក្រោមការឃុំខ្លួនបណ្តោះអាសន្ន១ឆ្នាំដំបូងនិងតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឲ្យពន្យារការឃុំខ្លួនបណ្តោះអាសន្នរយៈពេលអតិប្បរមា១ឆ្នាំ(រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩)។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលបដិសេធបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះសម្រេចថាការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការដែលមានលក្ខណៈចាំបាច់សម្រាប់បង្កាកុំឲ្យជនត្រូវចោទដាក់សម្ពាធដល់សាក្សីឬបំផ្លាញភស្តុតាង។ ជាងនេះទៀត អង្គបុរេជំនុំជម្រះយល់ឃើញថាការឃុំខ្លួនគឺមានលក្ខណៈចាំបាច់ដើម្បីធានាវត្តមានរបស់ជនត្រូវចោទក្នុងអំឡុងពេលកិច្ចនីតិវិធីនិងរក្សាសណ្តាប់ធ្នាប់សាធារណៈ។

សេចក្តីសង្ខេបនៃសេចក្តីសម្រេចត្រូវបានអានដោយ ឯកឧត្តម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះក្នុងកំឡុងពេលសវនាការជាសាធារណៈនាថ្ងៃនេះ។ សំណៅសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនឹងត្រូវផ្តល់ជូនតាមរយៈគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.eccc.gov.kh.

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**Lars Olsen**

មន្ត្រីទំនាក់ទំនងច្បាប់ អវតក

ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ០២៣

ទូរសព្ទលើតុ៖ +៨៥៥ (0) ២៣ ២១៩ ៨១៤

Ext.៦១៦៩

អ៊ីមែល៖ olsenl@un.org

បណ្ឌិត Helen Jarvis

ប្រធានកិច្ចការសាធារណ: អវតក

ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៣៤

ទូរសារ៖ +៨៥៥ (២៣) ២១៩ ៨៤១

**រាជ សម្បត្តិ**

មន្ត្រីព័ត៌មាន អវតក

ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦

ទូរសារ៖ +៨៥៥ (0)២៣ ២១៩ ៨៤១

អ៊ីមែល៖ reach.samath@eccc.gov.kh